ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៣៥ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបែងចែកចំណូលពីការពិន័យអន្តរការណ៍ និងការពិន័យជាប្រាក់ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ    រដ្ឋមន្ត្រីក្រសួងយុត្តិធម៌    រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៦ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ (+៨៥៥)២៣ ៨៦០ ៦៦៦

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ១៣៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញសេចក្តីសម្រេចលេខ១១៩ សសរ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាល ស្តីពីការប្រើប្រាស់ចំណូលមិនមែនសារពើពន្ធរបស់ក្រសួង ស្ថាប័នប្រមូលចំណូល សម្រាប់ការផ្តល់ការលើកទឹកចិត្តលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញប្រកាសអន្តរក្រសួងលេខ [illegible]...សហវ.ប្រក ចុះថ្ងៃទី១១... ខែ[illegible] ឆ្នាំ២០២១ ស្តីពីនីតិវិធីពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

ចំណូលពីការពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលប្រមូលបានដោយក្រសួងពាណិជ្ជកម្ម ត្រូវបានបែងចែកដូចខាងក្រោម ៖

១- បង់ចូលថវិកាជាតិ ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន
២- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន
៣- ប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន
៤- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យអន្តរការណ៍ដែលប្រមូលបាន។

**ប្រការ២ .-**

ចំណូលប្រមូលបានពីការផ្តន្ទាទោសពិន័យជាប្រាក់ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ដែលអនុវត្តតាមការសម្រេចរបស់តុលាការមានសមត្ថកិច្ច ត្រូវបានបែងចែកដូចខាងក្រោម៖

១- បង់ចូលថវិកាជាតិ ចំនួន ២៥%(ម្ភៃប្រាំភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន
២- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងពាណិជ្ជកម្ម ចំនួន ៤៩%(សែសិបប្រាំបួនភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៣- ប្រាក់រង្វាន់លើកទឹកចិត្តរបស់សាលាជម្រះក្តីពាក់ព័ន្ធសរុប ចំនួន ២៤%(ម្ភៃបួនភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៤- ប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន

៥- ប្រាក់រង្វាន់លើកទឹកចិត្តរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន ១%(មួយភាគរយ) នៃប្រាក់ពិន័យដែលប្រមូលបាន។

**ប្រការ៣ ._**

ប្រាក់រង្វាន់លើកទឹកចិត្តដែលផ្តល់ជូនក្រសួងពាណិជ្ជកម្ម សាលាជម្រះក្តីពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលកំណត់ក្នុងប្រការ១ និងប្រការ២ នៃប្រកាសអន្តរក្រសួងនេះ ត្រូវប្រើប្រាស់សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់និងមន្ត្រីផ្សេងៗទៀត និងពង្រឹងយន្តការប្រមូលចំណូល។

**ប្រការ៤ ._**

អនុញ្ញាតឱ្យក្រសួងពាណិជ្ជកម្ម បុរេប្រទានប្រាក់រង្វាន់លើកទឹកចិត្តពីចំណូលប្រមូលបានពីការពិន័យអន្តរការណ៍ លើអំពើល្មើសនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលរួមមាន ប្រាក់រង្វាន់របស់ក្រសួងពាណិជ្ជកម្ម ប្រាក់រង្វាន់សម្រាប់បង់ចូលមូលនិធិកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រាក់រង្វាន់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមការកំណត់ក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៥ ._**

ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រីរាជការ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

ខ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

គ. ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃសាលាជម្រះក្តី និងមន្ត្រីពាក់ព័ន្ធ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

**ប្រការ៦ ._**

ជារៀងរាល់ឆ្នាំ ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណាយប្រាក់រង្វាន់លើកទឹកចិត្តសរុប ដោយផ្អែកតាមអត្រាប្រាក់រង្វាន់ និងឥណទានចំណូលប្រចាំឆ្នាំដែលបានគ្រោង ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

រាល់កិច្ចប្រតិបត្តិការចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវកត់ត្រាឆ្លុះបញ្ចាំងនៅក្នុងថវិកាជាតិ ដូចកិច្ចប្រតិបត្តិការចំណាយដទៃទៀតរបស់ក្រសួងពាណិជ្ជកម្មដែរ។ ឥណទានចំណាយប្រាក់រង្វាន់ដែលបានគ្រោង ជាកម្មវត្ថុនៃការធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដើម្បីទូទាត់ជាមួយប្រាក់រង្វាន់ដែលបានបុរេប្រទានពីចំណូលថវិកាជាតិ។

**ប្រការ៧ ._**

ការទូទាត់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើឡើងប្រចាំខែ ដោយអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

**ក.ផ្នែកចំណូល**

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើសំណើសុំកត់ត្រាចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិនូវទឹកប្រាក់រង្វាន់សរុបដែលបានបុរេប្រទាន រួចបញ្ជូនមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល តារាងសម្រង់សលាកបត្របង់ចំណូលថវិកាជាតិ និងបណ្ណបង់ប្រាក់ តារាងស្តីពីការគណនាប្រាក់រង្វាន់ និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។

អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

**ខ.ផ្នែកចំណាយ**

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើសំណើសុំទូទាត់ចំណាយប្រាក់រង្វាន់សរុប និងធ្វើអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដោយចុះចំនួនទឹកប្រាក់ស្មើនឹងទឹកប្រាក់បុរេប្រទាន ដែលបានចុះក្នុងសលាកបត្របង់ចំណូលថវិកាជាតិ។

**ប្រការ៨ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ ._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **រដ្ឋមន្ត្រីក្រសួងយុត្តិធម៌** | **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន | **កើត រិទ្ធ** | **ប៉ាន សូរស័ក្តិ**

កន្លែងទទួល :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ